ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងព្រហ្មទណ្ឌ
លេខ: ១២
ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣

សាលដីកា

លេខ: ៥២
ចុះថ្ងៃទី១៤ខែមិថុនាឆ្នាំ២០០៦

# គោរពនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០៦ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅ:

១- ឯកឧត្តម ឃឹម ប៉ុណ្ណ ប្រធាន
២- លោក ឈឹម ស៊ីផល ចៅក្រម
៣- លោក វៀល មួន ចៅក្រម
៤- លោក យូរ ឧត្តរា ចៅក្រម
៥- លោក ប៉ែន សារឿន ចៅក្រមរបាយការណ៍

**ក្រឡាបញ្ជី**

អ្នកស្រី សុជុន សុមានីកា

**តំណាងមហាអយ្យការ**

លោក ឈួន ចាន់ថា ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ១៦ "ច" ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ១២ ចុះថ្ងៃទី១១ ខែកុម្ភៈឆ្នាំ២០០៣ របស់តុលាការកំពូល ។

**ចំពោះ:** បង្ករបួសស្នាមដោយចេតនា ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ខែកុម្ភៈ ឆ្នាំ២០០១ តាមមាត្រា៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

១-ជនជាប់ចោទឈ្មោះ កែវ សុគន្ធាវី ( ម្ចាស់បណ្តឹងសាទុក្ខ) ភេទស្រី អាយុ៣៣ឆ្នាំ ជាតិខ្មែរ មុខរបរ បុគ្គលិកអគ្គីសនី កើតនៅភូមិត្រាំង ឃុំអន្លង់រមៀត ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។ ទីលំនៅសព្វថ្ងៃផ្ទះលេខ១៤AEoz ផ្លូវ១១០ សង្កាត់ផ្សារដេប៉ូទី៣ ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ ។ ឪពុកឈ្មោះ កែវ ភួង (ស) ម្តាយឈ្មោះស្រី សារិន (រ) ប្តីឈ្មោះស៊ាង គីហុង មានកូន ០១នាក់ ។ ទោសពីមុនគ្មាន។

-មេធាវី : លោក ខៀវ សិព្វជន

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះឆៃ វិបុល "ចុងបណ្តឹងសាទុក្ខ" ភេទប្រុស អាយុ៣១ឆ្នាំ ជាតិខ្មែរ មុខរបរ បុគ្គលិកលីកាដូ សព្វថ្ងៃពុំមានបំរើការងារនៅអង្គការសិទ្ធិមនុស្សលីកាដូ ទៀតឡើយ ។

-ជនរងគ្រោះកុមារី ហុង វីដែន អាយុ៦ឆ្នាំ សព្វថ្ងៃស្នាក់នៅអង្គការសិទ្ធិមនុស្សលីកាដូ ។ មានម្តាយបិញ្ចឹមស្ត្រីខ្មែរ ឈ្មោះ ង៉ែត អ៊ុត ។

-មេធាវី : លោក យ៉ុង ផានិត

-តាមរបាយការណ៍របស់អង្គការការពារសិទ្ធិមនុស្សលីកាដូ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០១ បានបញ្ជាក់ថា កន្លងមកអង្គការយើងខ្ញុំ VCAO បានទទួលពត៌មានថា នៅផ្ទះលេខ១៤AEoz ផ្លូវ១១០ ក្រុម ១ ភូមិ១ សង្កាត់ផ្សារដេប៉ូ៣ ខ័ណ្ឌទួលគោក ដែលមានឈ្មោះកែវ សុគន្ធារី បំរើការងារនៅក្រុមហ៊ុនអគ្គីសនីកម្ពុជា តែងតែធ្វើទារុណកម្មជាញឹកញាប់លើកុមារីឈ្មោះ វីដែន អាយុ៧ឆ្នាំ ជាកូនចិញ្ចឹម ។ នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០១ អង្គការយើងខ្ញុំ បានចុះទៅដល់កន្លែងកើតហេតុ ហើយជួបកុមារីរងគ្រោះ ព្រមទាំងបានពិនិត្យស្លាកស្នាមលើរាងកាយឃើញមានសភាពធ្ងន់ធ្ងរ ដូចពត៌មានមែន ។ ជាមួយនោះអង្គការយើងខ្ញុំ VCAO បានសាកសួរពត៌មាននានាជុំវិញ ទារុណកម្មនេះ ព្រមទាំងបានថតរូបនិងស្លាកស្នាមទារុណកម្មលើរាងកាយកុមារីរងគ្រោះ ទុកជាភស្តុតាងសំរាប់ការពារតាមផ្លូវច្បាប់ ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ អមតុលាការក្រុងភ្នំពេញបានសំរេចៈ

ចោទប្រកាន់ឈ្មោះ កែវ សុគន្ធារី ភេទស្រី អាយុ៣៣ឆ្នាំ និងគូកន ពីបទៈ បង្ករបួសស្នាមដោយចេតនា ប្រព្រឹត្ត នៅខែកុម្ភៈ ឆ្នាំ២០០១ តាមមាត្រា៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

បញ្ជូនសំណុំរឿង វត្ថុតាង និងជនល្មើស ទៅចៅក្រមស៊ើបសួរក្រុងភ្នំពេញចាត់ការតាមច្បាប់ ស្តីពីនីតិវិធីព្រហ្មទណ្ឌជាធរមាន និងសុំ "ឃុំខ្លួន" ជនល្មើសជាបណ្តោះអាសន្ន។

-បានឃើញដីកាសំរេចលេខ២៣០៨ ត.ព្រ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០១ របស់ចៅក្រមស៊ើបអង្កេតតុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារ នៃសេចក្តីសំរេចដូចតទៅ :

១-ប្រគល់កុមារីឈ្មោះហុង វីដែន អាយុ៦ឆ្នាំ ជាតិខ្មែរ អោយស្ថិតក្រោមការគ្រប់គ្រងថែរក្សាជាបណ្តោះអាសន្ន របស់អង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្សលីកាដូ ។

២-ដីកាសំរេចនេះ មានអានុភាពអនុវត្តភ្លាម១ ។

-បានឃើញបណ្តឹងទាស់ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០១ របស់លោក ខៀវ សិព្វជន មេធាវីការពារឱ្យ កែវ សុគន្ធារី និងស៊ាង គីមហុង មិនសុខចិត្ត នឹងដីកាសំរេចលេខ ២៣០៨ ត.ព្រ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០១ របស់តុលាការក្រុងភ្នំពេញ ទាំងទំរង់ និងគតិច្បាប់ ។

-បានឃើញដីកាសំរេចលេខ៣៥៧៥ត.ព្រ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០១ របស់ចៅក្រមស៊ើបអង្កេតតុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារ នៃសេចក្ដីសំរេចដូចតទៅ :

+ បដិសេធពាក្យសុំធានាយកកូនមកចិញ្ចឹមបីបាច់ថែរក្សា ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០០១ របស់ឈ្មោះ កែវ សុគន្ធារី និងប្ដីឈ្មោះ ស៊ោង គីមហុង ត្រូវជាមាតាបិតាចិញ្ចឹមកុមារី ហុង រីដែន អាយុ៦ឆ្នាំ ជាតិខ្មែរ ចោលជាអសារបង់ ។

+ ដីកាសំរេចនេះមានប្រសិទ្ធភាព អនុវត្តភ្លាម ។

-បានឃើញបណ្ដឹងឧទ្ធរណ៍លេខ ១២ "ញ" ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០១ របស់លោក ខៀវ សិព្វផន ជាមេធាវីការពារ និងជាតំណាងឱ្យឈ្មោះ កែវ សុគន្ធារី និង ស៊ោង គីមហុង តវ៉ាមិនសុខចិត្តពីដីកាសំរេចលេខ៣៥៧៥ត.ព្រ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០១ របស់ចៅក្រមស៊ើបអង្កេតតុលាការក្រុងភ្នំពេញ លើសេចក្ដីសំរេចទាំងមូល ។

-បានឃើញសេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមសាលាឧទ្ធរណ៍ ថា :

១-ទទួលបណ្ដឹងឧទ្ធរណ៍លេខ១២ "ញ" ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០១ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់គតិច្បាប់ ។

២-តម្កល់ដីកាសំរេចលេខ៣៥៧៥ត.ព្រ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០១ របស់ចៅក្រមស៊ើបអង្កេត ទុកជាបានការតទៅ ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ១៦"ច" ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០២ របស់សាលា-ឧទ្ធរណ៍ ដែលមានខ្លឹមសារ នៃសេចក្ដីសំរេចដូចតទៅ:

១-ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០១ របស់លោកមេធាវី ខៀវ សិព្វផន ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់ នឹងគតិច្បាប់ ។

២-តម្កល់ដីកាសំរេចលេខ៣៥៧៥ ត.ព្រ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០១ របស់ចៅក្រមស៊ើបអង្កេតតុលាការក្រុងភ្នំពេញ ទុកជាបានការដដែល ។

៣-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី បើកផ្លូវប្ដឹងសាទុក្ខតាមកំណត់ច្បាប់ ។

-បានឃើញបណ្ដឹងសាទុក្ខលេខ១៥ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ របស់ឈ្មោះ កែវ សុគន្ធារី តវ៉ាប្ដឹងមិនសុខចិត្ត ពីសាលដីកាព្រហ្មទណ្ឌលេខ១៦"ច" ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០២ របស់សាលា-ឧទ្ធរណ៍ លើសេចក្ដីសំរេចទាំងមូល ។

-បានឃើញសារណាការពារ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៣ របស់លោក ខៀវ សិព្វផន តំណាង

ឱ្យឈ្មោះកែវ សុគន្ធាវី ។

-បានឃើញសារណាតប ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៦ របស់លោក យុង ផានិត ជាមេធាវីការពារឱ្យកុមារី ហុង វីដែន និងលោកស្រី ណាលីពីឡូក ។

-បានស្ដាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមតុលាការកំពូលថា: ជនជាប់ចោទត្រូវបានចោទ ពីបទ បង្ករបួសស្នាមដោយចេតនា ប្រព្រឹត្តនៅខែកុម្ភៈ ឆ្នាំ២០០១ តាមមាត្រា៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល គប្បីមិនឱ្យជនជាប់ចោទគ្រប់គ្រង និងថែរក្សាលើកុមារីរងគ្រោះ ហុង វីដែន ឡើយ ។ សូមតម្កល់សាលដីកាសាលាឧទ្ធរណ៍ ទុកជាបានការទាំងមូល ។

-បានស្ដាប់ចម្លើយអះអាងរបស់ឈ្មោះ កែវ សុគន្ធាវី នាពេលសវនាការថា:

+ នាងខ្ញុំជាម្ដាយទៅសុំឱ្យជួបកូន វីដែន គេមិនព្រមឱ្យជួបកូនទាល់តែសោះ ហើយមានភាពរញ៉េរញ៉ៃ ។

+ នៅពេលចាប់កូនស្រីនាងខ្ញុំ ដោយគ្មានដីកាបង្គាប់ឱ្យចាប់របស់តុលាការអ្វីទាំងអស់ ហើយពេលចាប់ គឺគ្មានដីកាសំរេចឱ្យគ្រប់គ្រង និងថែរក្សាកូនស្រីនាងខ្ញុំទេ ។

+ នាងខ្ញុំបានប្ដឹង គឺនៅពេលអង្គការលីកាដូចាប់កូននាងខ្ញុំ មានរយៈពេល២ខែ ដោយគ្មានលិខិតគ្រប់គ្រងកូនទេ ហើយក៏ពុំទាន់មានការចោទប្រកាន់ពីតុលាការដែរ ។

+ ខ្ញុំជាម្ដាយ ដោយមានលិខិតពីព្រះរាជអាជ្ញា អ៊ុក សាវុធ ដើម្បីទៅសុំជួបកូនស្រីខ្ញុំ ក៏គេមិនឱ្យជួបកូនទៀត ។

+ នាងខ្ញុំពុំមានធ្វើអ្វីខុសធំដុំទេ គ្រាន់តែក្ដិច ប្រដៅប្រដៅកូនបន្តិចបន្តួចប៉ុណ្ណោះ ពុំមានធ្វើទារុណកម្មអ្វីលើកូនស្រី វីដែន ឡើយ ។

+ នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០១ មានរបួសក្បាលធន់ស្រាល នៅទ្រនាប់ជើងសក់ គឺបណ្ដាលមកពីរអិលដួលនៅបន្ទប់ទឹក ប៉ះក្បាលនឹងកាំជណ្ដើរ ។

<u>សំណូមពរ</u>: នាងខ្ញុំសុំឱ្យតុលាការប្រគល់កូនស្រី ហុង វីដែន មកគ្រប់គ្រង និងថែរក្សាវិញ ។

-ក្រឡាបញ្ជីអានសារណាតបរបស់មេធាវីតំណាងឱ្យដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ នៃ វិបុល ។

-បានស្ដាប់ចម្លើយអះអាងរបស់លោកស្រី វេជ្ជ បណ្ឌិត ពុង ឈីវកេក ជាប្រធានអង្គការ លីកាដូ និងជាប្រធានសំរបសំរួលអង្គការសម្ព័ន្ធស្ត្រី ហៅកាត់ ខេម បូ នាពេលសវនាការថា:

+ ឆ្នាំ២០០១ មិនមែនអង្គការ លីកាដូ ទៅចាប់ក្មេងស្រី វីដែន នោះ ដូចអ្នកស្រី

កែវ សុគន្ធារី ចោទទេ ។ យើងខ្ញុំមិនខែនទៅតែឯកឯង ព្រោះខ្ញុំជាអង្គការ មិនមែនរដ្ឋាភិបាលទេ គឺធ្វើអ្វីខ្លាចណាស់ច្បាប់ទំលាប់ នៅពេលទៅជួយរំដោះក្មេងស្រីនោះ គឺមានអន្តរាគមន៍ ស្ថាប័នអាជ្ញាធរ ដែនដី និងអង្គការគាំពារកុមារ ផ្តល់ពត៌មានឱ្យជួយសង្គ្រោះ រួមជាមួយមន្ត្រីសាលាសង្កាត់ផ្សារដេរម៉្ញ៉ា និងប៉ូលីស ។

+ ក្មេងស្រី វីដែន មានអាយុ៧ឆ្នាំ តែនាងចេះឆ្លើយទាំងអស់ ។ ក្មេងនេះបានស្ទុះមកអោបជើងមន្ត្រីនគរបាលម្នាក់សុំអង្វរឱ្យជួយ ហើយឃើញមានស្លាមជាំពេញខ្លួនប្រាណ មន្ត្រីស្ត្រីនោះបានអោប យំស្រណោះដោយអាណិតអាសូរ ។

+ វេជ្ជបណ្ឌិតអង្គការលីកាដូ បានព្យាបាល វីដែន ហើយក៏មានបញ្ហាសុខភាពលើរាងកាយ និងផ្លូវចិត្តសំខាន់ណាស់ ជាផលវិបាកបន្សល់ទុក ត្រូវទទួលការពិគ្រោះយោបល់ជាច្រើនខែ ក្នុងការជួយសំរួលស្មារតីនាងឡើងវិញ ។

+ ២ខែក្រោយមកបានយកកូនស្រីឱ្យចូលរៀនសាលា

+ ១ខែក្រោយ យើងខ្ញុំបានសុំឱ្យតុលាការចេញដីកាសំរេចឱ្យអង្គការ លីកាដូ មិនមែនរដ្ឋាភិបាលគ្រប់គ្រង និងថែរក្សាក្មេងស្រីនេះ ។

+ យើងខ្ញុំមានបំណងចង់តែជួយកូនខ្មែរ ព្រោះខ្ញុំក៏ជាខ្មែរមួយរូបដែរ ក្រោមការគ្រប់គ្រង និងថែរក្សា នាងមានទំនាក់ទំនងជាមួយឪពុកជាប្រចាំ ។

+ តើអង្គការជួយកុមារ និងបញ្ជូនកុមារចូលក្នុងសង្គមវិញទេ ?

+ ក្មេងស្រីមានទំនាក់ទំនងល្អរវាងឪពុក-បងប្អូន និងមជ្ឈដ្ឋានខាងក្រៅ ហើយបានឱ្យទៅរៀនសូត្រ ជាសិស្សល្អ រៀនសូត្រពូកែ ។

+ បានពិគ្រោះផ្លូវចិត្ត នាងខ្ញុំសង្ឃឹមថា កូនស្រីនេះចូលក្នុងសង្គម បំរើសង្គមយើង ឱ្យក្លាយទៅជាប្រជាពលរដ្ឋល្អ ។

-បានស្តាប់ចម្លើយអះអាងរបស់កុមារី រឿន រតនា ហៅ ហុង វីដែន មានអាយុ១៣ឆ្នាំ សព្វថ្ងៃរស់នៅជាមួយអង្គការ លីកាដូ នាពេលសវនាការថា :

+ ខ្ញុំបានស្នាក់នៅក្នុងអង្គការ លីកាដូ មានរយៈពេល៦ឆ្នាំហើយ

+ ខ្ញុំបានទៅរៀនសាលាចាប់តាំងពីថ្នាក់ទី១ រហូតដល់ថ្នាក់ទី៦

+ ពុំមាននរណាវាយធ្វើបាបខ្ញុំទេ ខ្ញុំចង់រស់នៅជាមួយអង្គការ លីកាដូ ។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក ខៀវ សិព្វផន មេធាវីការពារជនជាប់ចោទ នាពេលសវនាការថា: តាមស្តាប់របាយការណ៍របស់មេធាវី គឺពិរោះណាស់ តែវាមិនមែនជាការពិតទេ ។

+ ពេលចាប់កុមារី វីដែន នាងជាម្ដាយភ័យណាស់ ក្រោយពីម្ដាយយកកូនមកពីមន្ទីរពេទ្យ ចាប់ដោយគ្មានការយល់ព្រមពីឪពុកម្ដាយ គ្មានដីកា គ្មានសាលក្រមរបស់តុលាការអ្វីទាំងអស់ ។

+ ម្ដាយសុំជួបកូន មិនឱ្យជួប រហូតដល់មេធាវីសុំជួប មិនឱ្យជួបទាល់តែសោះ ។ អង្គការ លីកាដូ មកធ្វើការស្រុកខ្មែរ គឺអង្គការការពារសិទ្ធិមនុស្ស តែបែរជារំលោភសិទ្ធិមនុស្ស រឿងអីមិនឱ្យម្ដាយគេជួបកូនគេ គិតតែឆ្នៃប្រឌិតខ្សែវីដេអូ មានបញ្ហាក្លែងបន្លំបំភ័ន្តមតិតុលាការឱ្យជឿតាម ។

+ លោកចៅក្រម ហាម ម៉េងសែ តុលាការក្រុងភ្នំពេញ ចេញដីកាលេខ៣៥៧៥ត.ព្រ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០១ សំរេចប្រគល់កូនទៅឱ្យអង្គការ លីកាដូ គ្រប់គ្រងបណ្ដោះអាសន្ន គឺខុសទាំងទំរង់ ខុសទាំងគតិច្បាប់ ។

+ ក្មេងតូចប៉ុណ្ណឹង មានទោសក្បត់ជាតិឯណា គ្រាន់តែម្ដាយសុំជួបកូនមិនឱ្យជួបរហូតដល់សព្វថ្ងៃ ។

+ សូមតុលាការពិនិត្យពិចារណា អំពីសំបុត្រពេទ្យ ប្រាក់ សេងហួរ និងសំបុត្រពេទ្យបង្អែកក្រុង ។

+ កូនក្ដីខ្ញុំបាទមិនត្រូវមានទោសទេ សុំបដិសេធដីកាសំរេចតុលាការក្រុងភ្នំពេញ និងសាលដីកាសាលាឧទ្ធរណ៍ចោលទាំងមូល និងសុំឱ្យអ្នកស្រី ស្រី សារិន ជាជីដូនបង្កើត ចិញ្ចឹមថែរក្សាជាអាជ្ញាកណ្ដាល ។

-បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់លោក យុង ផានិត មេធាវីការពារឱ្យកុមារី ហុង វីដែន នាពេល-សវនាការថា: លីកាដូ គ្រាន់តែជាអង្គការមួយការពារសិទ្ធិមនុស្ស ជួយសង្គ្រោះមនុស្ស ។ នៅថ្ងៃកើតហេតុ ទាក់ទងទៅនឹងកុមារី វីដែន ត្រូវបានវាយដុំជារឿងព្រហ្មទណ្ឌ ។ លោកចៅក្រមបន្ទុកគាត់បានចុះពិនិត្យផ្ទាល់ យល់ថាជាបទល្មើសព្រហ្មទណ្ឌ ។

+ មានអង្គការ លីកាដូ ជួយគ្រប់គ្រង និងថែរក្សាបណ្ដោះអាសន្ន និងក្នុងច្បាប់មានសមត្ថកិច្ចប្រគល់ក្មេងស្រី វីដែន ឱ្យអង្គការត្រឹមត្រូវ ។

+ រួមទាំងមេធាវី ទាំងឪពុកម្ដាយ បានឃើញការធ្វើទារុណកម្មនេះ ពិតប្រាកដមែន ។ តុលាការក្រុងភ្នំពេញចេញដីកាសំរេចប្រគល់ឱ្យអង្គការ លីកាដូ នេះ មិនមែនធ្វើជាអាណាព្យាបាលរហូតទេ គឺគ្រាន់តែគ្រប់គ្រងបណ្ដោះអាសន្ន ។

+ ការសុំជួប ហេតុអ្វីមិនឱ្យជួប ? នៅពេលសុំជួបអង្គការយើងខ្ញុំបានសួរកុមារី តែក្មេងស្រីនេះមិនព្រមចង់ជួបទេ រហូតដល់សព្វថ្ងៃនេះមិនមែនអង្គការ យើងមិនឱ្យជួបកូនទេ គឺកូនមិនព្រមចង់ជួបម្ដាយរបស់ខ្លួន ។

+ សូមតម្កល់ដីកាសំរេចរបស់តុលាការក្រុង និងសាលដីកាសាលាឧទ្ធរណ៍ទុកទាំងមូល ។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការ អមតុលាការកំពូលថាៈ រដ្ឋាភិបាលកម្ពុជាកំពុងយកចិត្តទុកដាក់លើអំពើហិង្សាក្នុងគ្រួសារ និងសិទ្ធិកុមារ ។ មន្ទីរពេទ្យ ប្រាក់ សេងហួរ ជាពេទ្យឯកជន ផ្ទុយគ្នា និងមន្ទីរពេទ្យបង្អែកក្រុងជាពេទ្យរដ្ឋ ដោយជនជាប់ចោទត្រូវចោទ ពីបទ បង្ករបួសស្នាមលើកុមារី ហុង វីដែន តាមមាត្រា៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល កាលពីខែ០២ ឆ្នាំ២០០១ ។ ដូច្នេះ មិនអាចឱ្យជនជាប់ចោទគ្រប់គ្រងថែរក្សា លើកុមារីនេះ បានទៀតឡើយ ។

+ សូមតុលាការសំរេចឱ្យកុមារីរស់នៅដោយមានសុវត្ថិភាព មានម្ហូបអាហារគ្រប់គ្រាន់ បានរៀនសូត្រ ចូលក្នុងសង្គមបាន ។

+ ហេតុដូច្នេះ សាលដីការបស់សាលាឧទ្ធរណ៍ ដែលសំរេចមកនេះមានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយ ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់ឈ្មោះ កែវ សុគន្ធារី សារណារបស់លោកមេធាវីរបស់អង្គការលីកាដូ . ចម្លើយរបស់លោកស្រី ប្រធានអង្គការ លីកាដូ . ចម្លើយរបស់កុមារី ហុង វីដែន និងសេចក្តីសន្និដ្ឋានរបស់មេធាវីជនជាប់ចោទ និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ។

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## <u>តុលាការកំពូល</u>

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ១៥ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ របស់ កែវ សុគន្ធារី ធ្វើឡើងក្នុងកំនត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា តាមលទ្ធផលនៃកោសល្យវិច័យពេទ្យលេខ២១/០១ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០០១ បញ្ជាក់ថា ពិតជាមានអំពើទារុណកម្មទៅលើកុមារីរងគ្រោះឈ្មោះ ហុង វីដែន ដែលស្ថិតក្នុងវ័យអនីតិជន ដូច្នេះការសំរេចប្រគល់កុមារីរងគ្រោះឈ្មោះហុង វីដែន ឱ្យទៅអង្គការ លីកាដូ បីបាច់ថែរក្សាជាបណ្តោះអាសន្ន គឺជាការចាំបាច់បំផុត ដើម្បីការពារកុមារីនេះពីអំពើហិង្សាផ្សេងៗទៀត ដែលអាចនឹងកើតមានឡើង ។

-យល់ឃើញថា ការដែលមេធាវីជនជាប់ចោទ លើកឡើងនាសវនាការនេះថា ការដែលតុលាការអង្គសេចក្ដីដែលសំរេចឱ្យអង្គការ លីកាដូ គ្រប់គ្រងកុមារីជាបណ្ដោះអាសន្នធ្វើឡើងដោយខុសនីតិវិធីនោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះនេះជាវិធានការបណ្ដោះអាសន្នចាំបាច់ ដើម្បីធានាសេចក្ដីសុខ និងសុវត្ថិភាព របស់កុមារដែលជាកម្មវត្ថុនៃបទចោទ ។ ហើយការដែលលើកឡើងអំពីលិខិតពេទ្យ និងការបង្ករបួសស្នាមផ្សេងទៀតនោះ ជារឿងនៃអង្គសេចក្ដីដែលតុលាការកំពូលពុំអាចពិចារណាទេ នៅពេលនេះ ។

-យល់ឃើញថា នាសវនាការនេះលោកមេធាវីរបស់ជនជាប់ចោទបានជូនមកតុលាការនូវលិខិតរបស់អ្នកស្រី ស្រី សារិន ដែលអះអាងថា ជាជីដូនបង្កើតរបស់កុមារី ហុង វីដែន និងជាម្ដាយរបស់ឈ្មោះកែវ សុគន្ធារី ដែលសុំយកចៅ គឺកុមារី ហុង វីដែន ទៅថែរក្សាដោយផ្ទាល់នោះ តុលាការកំពូលពុំអាចពិចារណាបានទេ ពីព្រោះជាសំណូមពរថ្មី ដែលតុលាការថ្នាក់ក្រោមពុំទាន់បានពិចារណានៅឡើយ ។

-យល់ឃើញថា ការដែលតុលាការក្រុងភ្នំពេញ ក៏ដូចសាលាឧទ្ធរណ៍ដែរ ដែលសំរេចឱ្យកុមារី ហុង វីដែន ស្ថិតក្រោមការគ្រប់គ្រងបណ្ដោះអាសន្នរបស់អង្គការ លីកាដូ នោះ ពុំទាន់មានលក្ខណៈគ្រប់ជ្រុងជ្រោយទេ គប្បីតុលាការកំពូលពិចារណា និងសំរេចបន្ថែមអំពីការត្រួតពិនិត្យក្នុងការគ្រប់គ្រងនេះ ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ១៦"ច" ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ដែលសំរេចសេចក្ដីមកនេះមានលក្ខណៈត្រឹមត្រូវទាំងទំរង់ និងគតិច្បាប់ហើយ ។

## ដោយហេតុដូច្នេះ

## វិនិច្ឆ័យសេចក្ដីចំពោះមុខជនជាប់ចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី

១-ទទួលបណ្ដឹងសាទុក្ខលេខ១៥ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ របស់ឈ្មោះកែវ សុគន្ធារី ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុស និងគតិច្បាប់ ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ១៦"ច"ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ទុកជាបានការ ដោយសំរេចបន្ថែមថា ការគ្រប់គ្រងថែរក្សាជាបណ្ដោះអាសន្ននេះ ត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់អយ្យការ អមតុលាការក្រុងភ្នំពេញ ។

៣-បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ១២ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣ របស់តុលាការកំពូល ទៅតុលាការក្រុងភ្នំពេញ ដើម្បីបញ្ចូលក្នុងរឿងនៃអង្គសេចក្ដី ។

៤-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី១៤ ខែមិថុនាឆ្នាំ ២០០៦ ។